**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ២៨៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់ឈ្មោះផ្លូវចំនួន ៤(បួន)ខ្សែ នៅក្រុងសៀមរាប ខេត្តសៀមរាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ ស្តីពីបែបបទ និងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ
- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកែប្រែឧបសម្ព័ន្ធអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ ស្តីពីបែបបទ និងនីតិវិធីនៃការដាក់ឈ្មោះផ្លូវឬលេខផ្លូវ និងការកែប្រែឈ្មោះផ្លូវឬលេខផ្លូវ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ដាក់ឈ្មោះផ្លូវចំនួន៤(បួន)ខ្សែ នៅក្រុងសៀមរាប ខេត្តសៀមរាប ដូចខាងក្រោម៖

១-**វិថីជ័យវរ្ម័នទី៧** (Jayavarman VII Rd.) ចាប់ពីចំណុចផ្លូវបំបែកមហាវិថីហ្សាលដឺហ្គោល ដល់ចំណុចកែងផ្លូវ B.999 មានប្រវែង ៣ ០៤៥(បីពាន់សែសិបប្រាំ)ម៉ែត្រ។

២-**មហាវិថីសូរ្យវរ្ម័នទី២** (Suryavarman II Blvd.) ចាប់ពីចំណុចស្ពានថ្ម ដល់ចំណុចផ្លូវបំបែកផ្លូវមិត្តភាពសៀមរាប-ជីដាង មានប្រវែង ៣ ១២០(បីពាន់មួយរយម្ភៃ)ម៉ែត្រ។

៣-**វិថីជ័យវរ្ម័នទី២** (Jayavarman II Rd.) ចាប់ពីចំណុចស្ពានថ្ម ដល់ផ្លូវ C.899 មានប្រវែង ៤ ៩៦៣(បួនពាន់ប្រាំបួនរយហុកសិបបី)ម៉ែត្រ។

៤-**វិថីហ្សាលដឺហ្គោល** (Charles de Gaulle Ave.) ចាប់ពីចំណុចស្តុបសណ្ឋាគារសុខាអង្គរ ដល់ចំណុចរង្វង់មូលជ័យវរ្ម័នទី៧ មានប្រវែង ៥ ៣៤២(ប្រាំពាន់បីរយសែសិបពីរ)ម៉ែត្រ។

តារាងពិពណ៌នាអំពីផ្លូវទាំង៤(បួន)ខ្សែ ជាឧបសម្ព័ន្ធភ្ជាប់នឹងអនុក្រឹត្យនេះ។

**មាត្រា ២.-**

រដ្ឋបាលខេត្តសៀមរាបត្រូវផ្លាស់ប្តូរផ្លាកឈ្មោះផ្លូវទាំង៤(បួន)ខ្សែនេះ និងផ្សព្វផ្សាយជាសាធារណៈឱ្យបានទូលំទូលាយ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៩កើត ខែ បឋមាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ៦ ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**
សូមហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ៤
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២៩៧ អនក្រ.បក ចុះថ្ងៃទី ២ ខែ [illegible] ឆ្នាំ២០២២
ស្តីពីការដាក់ឈ្មោះផ្លូវចំនួន៤(បួន)ខ្សែ នៅក្រុងសៀមរាប ខេត្តសៀមរាប

**តារាងពិពណ៌នាអំពីផ្លូវទាំង៤(បួន)ខ្សែ**

| ល.រ | ឈ្មោះផ្លូវ | ចំណុចចាប់ផ្តើម | ចំណុចបញ្ចប់ | ប្រវែង គិតជាគីឡូម៉ែត្រ (គ.ម) |
|---|---|---|---|---|
| ១. | **វិថីជ័យវរ្ម័នទី៧** (Jayavarman VII Rd.) | ផ្លូវបំបែកមហាវិថីហ្សាលដឺហ្គោល | កែងផ្លូវ B.999 | ៣,០៤ |
| ២. | **មហាវិថីសូរ្យវរ្ម័នទី២** (Suryavarman II Blvd.) | ស្ពានថ្ម | ផ្លូវបំបែកផ្លូវមិត្តភាពសៀមរាប-ជីជាង | ៣,១២ |
| ៣. | **វិថីជ័យវរ្ម័នទី២** (Jayavarman II Rd.) | ស្ពានថ្ម | ផ្លូវ C.899 | ៤,៩៦ |
| ៤. | **វិថីហ្សាលដឺហ្គោល** (Charles de Gaulle Ave.) | ស្តុបសណ្ឋាគារសុខាអង្គរ | រង្វង់មូលជ័យវរ្ម័នទី៧ | ៥,៣៥ |